ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តសៀមរាប
គណៈកម្មាធិការលទ្ធកម្ម
លេខ:០០៤/០១៩........រសស.សជណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់ឧបករណ៍បរិក្ខារអគ្គិសនី និងមេកានិច

រដ្ឋាករទឹកស្វយ័តសៀមរាប សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តសៀមរាប នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់ឧបករណ៍បរិក្ខារអគ្គិសនី និងមេកានិច។

រដ្ឋាករទឹកស្វយ័តសៀមរាប បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃរដ្ឋាករទឹកស្វយ័តសៀមរាប ដែលមានអាសយដ្ឋានស្ថិតនៅទីតាំងខាងកើតស្ពានថ្មព្រះរាជដំណាក់ ជាប់ផ្លូវជាតិលេខ៦ ភូមិស្លក្រាម សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ចាប់ពី ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ ដល់ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ០៦៣ ៩៦៣ ០២៥)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅវេលាម៉ោង១០ម៉៣០នាទីព្រឹក ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅ នៅវេលាម៉ោង១០ម៉៣០នាទីព្រឹក ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩ នៅរដ្ឋាករទឹកស្វយ័តសៀមរាប តាមអាសយដ្ឋានខាងលើ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃអង្គារ ៣កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
ធ្វើនៅសៀមរាប ថ្ងៃទី ៨ ខែមករា ឆ្នាំ ២០១៩
ជ. ប្រធានគណៈកម្មាធិការលទ្ធកម្ម
អនុប្រធានទី១

ចាន់ សេងឡា

ចម្លងជូន៖
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
  "ដើម្បីជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ